www.clbs.asia



# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..០៣..សសរ.

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង សម្រាប់រៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣ មីនា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៨អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ០៦អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតទិវាវប្បធម៌ជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងសម្រាប់រៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោកជំទាវ | **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- ឯកឧត្តម | **ច័ន្ទ តានី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តម | **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | អនុប្រធាន |
| ៤-ឯកឧត្តម | **ទី តាឃី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- ឯកឧត្តមនាយឧត្តមសេនីយ៍ | **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦- ឯកឧត្តម | **អ៊ុក ប្រជា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧-លោកជំទាវ | **ច័ន្ទ ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិកា |
| ៨- ឯកឧត្តម | **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |

៩- លោកជំទាវ **អ៊ឹម ស៊ីថៃ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិកា
១០- លោកជំទាវ **ឆួច សារ៉ុម** រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា សមាជិកា
១១- ឯកឧត្តម **សូន ឈាងលី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
១២- លោកជំទាវ **ឃុន រចនា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិកា
១៣- ឯកឧត្តម **តាន់ ឌុដ្ឋា** ទីប្រឹក្សាក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
១៤- ឯកឧត្តម លោកជំទាវ អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក។

**ប្រការ២ .-**

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើសារាចរណែនាំស្តីពីការរៀបចំប្រារព្ធពិធី **«ទិវាវប្បធម៌ជាតិ ៣មីនា»**
- រៀបចំប្រធានបទ ខ្លឹមសារ រូបភាពបម្រើឱ្យ **«ទិវាវប្បធម៌ជាតិ»** ក្នុងឆ្នាំនីមួយៗ
- បំផុសនិងអំពាវនាវគ្រប់មជ្ឈដ្ឋាន និងសប្បុរសជន ដើម្បីជួយឧបត្ថម្ភគាំទ្រ **«ទិវាវប្បធម៌ជាតិ»**
- ទទួលភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ .-**

គណៈកម្មការនេះ ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅទីស្តីការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ និងអាចបង្កើតអនុគណៈកម្មការមួយចំនួន តាមការចាំបាច់ ដែលអនុគណៈកម្មការនីមួយៗ ត្រូវដឹកនាំដោយប្រធាន ០១(មួយ)រូប។

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីសម្រួលដល់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៤ .-**

អនុប្រធាន និងសមាជិកនៃគណៈកម្មការនេះ និងប្រធាន និងសមាជិកនៃអនុគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវជួយសម្របសម្រួលថវិកាជូនគណៈកម្មការនេះ តាមតម្រូវការជាក់ស្តែង។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ